# សេចក្តីប្រកាសព័ត៌មាន

នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១១ វេលាម៉ោង ១១:០០ ព្រឹក នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា **ឯកឧត្តម គូនីញ៉ូ មីគូរីយ៉ា** (Kunio Mikuriya) អគ្គលេខាធិការអង្គការគយពិភពលោក (WCO) បានចូលជួបសំដែងការគួរសមជាមួយ **ឯកឧត្តមបណ្ឌិត ម៉ែន ស៊ីម៉ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា** ។ ការចូលជួបសំដែងការគួរសមនេះ ជាផ្នែកមួយនៃដំណើរទស្សនកិច្ចផ្លូវការជាប្រវត្តិសាស្ត្រលើកទីមួយមកកាន់ព្រះរាជាណាចក្រកម្ពុជា របស់លោកអគ្គលេខាធិការអង្គការគយពិភពលោក ចាប់តាំងពីអង្គការនេះត្រូវបានបង្កើតឡើងនាឆ្នាំ ១៩៥២ ដែលពេលនោះមានឈ្មោះថា ក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការគយ (Customs Cooperation Council) និងជាលើកទីមួយផងដែរ ចាប់តាំងពីអង្គភាពគយនិងរដ្ឋាករកម្ពុជាចាប់បដិសន្ធិឡើងនៅឆ្នាំ ១៩៥១ ។

បន្ទាប់ពីការថ្លែងស្វាគមន៍របស់ **ឯកឧត្តមបណ្ឌិត ម៉ែន ស៊ីម៉ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា** លោកអគ្គលេខាធិការអង្គការគយពិភពលោកបានសំដែងនូវមនោសញ្ចេតនារំភើបក្រៃលែង ចំពោះការទទួលរាក់ទាក់យ៉ាងកក់ក្តៅពីសំណាក់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងមន្ត្រីគយនិងរដ្ឋាករកម្ពុជាទាំងអស់ ។ លោកអគ្គលេខាធិការ បានធ្វើការវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនលូតលាស់ដ៏ឆាប់រហ័សរបស់ព្រះរាជាណាចក្រកម្ពុជាលើគ្រប់វិស័យ ជាពិសេសការអនុវត្តកម្មវិធីទំនើបកម្មរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។ លើសពីនេះទៀត ឯកឧត្តម **គូនីញ៉ូ មីគូរីយ៉ា** ក៏បានកោតសរសើរយ៉ាងខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងឋានៈជាម្ចាស់ផ្ទះ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការចូលរួមរៀបចំកិច្ចប្រជុំថ្នាក់អគ្គនាយកគយអាស៊ាន-ជប៉ុន ជាមួយ ADB និង WCO កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ កន្លងទៅនេះ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យគួរជាទីពេញចិត្ត ។

បន្ទាប់មក លោកអគ្គលេខាធិការអង្គការគយពិភពលោកបានគូសបញ្ជាក់ពីគោលបំណងនៃដំណើរទស្សនកិច្ចផ្លូវការជាប្រវត្តិសាស្ត្រនេះ ថាមានគោលបំណងដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយកម្ពុជា ជាមួយ WCO ក៏ដូចជាជម្រុញការធ្វើសមាហរណកម្មរដ្ឋបាលគយ ទៅក្នុងកម្រិតតំបន់ និងកម្រិតពិភពលោកផងដែរ ។ ទស្សនកិច្ចនេះ ត្រូវបានធ្វើឡើងស្របតាមបេសកកម្មរបស់ WCO ក្នុងការពង្រឹងនូវសមត្ថភាព និងប្រសិទ្ធភាពរដ្ឋបាលគយនៃបណ្តាប្រទេសជាសមាជិក ក្នុងការលើកកម្ពស់អនុលោមភាពច្បាប់ កាត់បន្ថយបទល្មើសគយ ដើម្បីរួមចំណែកសម្រេចគោលដៅនៃកិច្ចសម្រួលពាណិជ្ជកម្ម បង្កើនការប្រមូលចំណូល ធានាសន្តិសុខខ្សែចង្វាក់នៃការបញ្ជូនទំនិញ និងឈានទៅបង្កើនការរីកលូតលាស់សេដ្ឋកិច្ចជាតិ ។

ជាកិច្ចបន្ត កិច្ចសំណេះសំណាលគ្នាក៏បានផ្តោតលើប្រធានបទសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការគយដើម្បីឈានទៅសម្រេចបាននូវគោលដៅនៃកិច្ចសម្រួលពាណិជ្ជកម្ម ដូចជា ÷ ការអនុវត្តប្រព័ន្ធប្រតិបត្តិករសេដ្ឋកិច្ចដែលបានផ្តល់សិទ្ធិ (Authorized Economic Operator - AEO), កិច្ចព្រមព្រៀងនៃការទទួលស្គាល់ទៅវិញទៅមកនៃ AEO (AEO Mutual Recognition Agreement), ការសិក្សាពីរយៈពេលបំពេញបែបបទបញ្ចេញទំនិញពីគយ (Time Release Studies), និងកម្មវិធីសិក្សាតាមមធ្យោបាយអេឡិចត្រូនិច (E-Learning Program) របស់ WCO ជាដើម ។ល។

ការជួបសំដែងការគួរសមនេះ ត្រូវបានបញ្ចប់នៅវេលាម៉ោង ១២:០០ ថ្ងៃត្រង់ បន្ទាប់ពីឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានអញ្ជើញគណៈប្រតិភូទស្សនានូវសមិទ្ធផលនានា ដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាសម្រេចបានកន្លងមក ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១១